ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...០១...សសរ.......

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការស្រាវជ្រាវនិងអភិវឌ្ឍន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/១០២៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញអនុក្រឹត្យលេខ ៤៨អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលសរសេរជាអក្សរកាត់ថា **គ.ស.អ.** ដើម្បីជួយលើការងារគ្រប់គ្រងការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(**ក.ជ.វ.ប.ន.**)។

**ប្រការ២ .-**

**គ.ស.អ.** មានតួនាទីជាសេនាធិការជូន **ក.ជ.វ.ប.ន.** និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព របៀបវារៈស្រាវជ្រាវជាតិនិងយន្តការអនុវត្តន៍សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ក្នុងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដាក់ជូន **ក.ជ.វ.ប.ន.** ពិនិត្យនិងសម្រេច
- ផ្សព្វផ្សាយនិងសម្របសម្រួលការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព របៀបវារៈស្រាវជ្រាវជាតិនិងយន្តការអនុវត្តន៍សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព របៀបវារៈស្រាវជ្រាវជាតិនិងយន្តការអនុវត្តន៍សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍
- ពិនិត្យ សិក្សា ស្រាវជ្រាវ និងវិភាគលើការអភិវឌ្ឍតាមវិស័យជាអាទិភាពនិងកំណត់របៀបវារៈស្រាវជ្រាវជាតិ
- រៀបចំសៀវភៅណែនាំ គោលការណ៍ណែនាំ និងបទប្បញ្ញត្តិសម្រាប់កិច្ចការស្រាវជ្រាវនិងអភិវឌ្ឍន៍ដើម្បីដាក់ជូន **ក.ជ.វ.ប.ន.** ពិនិត្យនិងសម្រេច
- ពិនិត្យ វិភាគ និងវាយតម្លៃលើសមិទ្ធផលនិងផលជះដែលទទួលបានពីកម្មវិធីស្រាវជ្រាវនិងអភិវឌ្ឍន៍ក្រោមមូលនិធិស្រាវជ្រាវជាតិ
- សហការ សម្របសម្រួល និងភ្ជាប់ទំនាក់ទំនងជាមួយស្ថាប័នជាតិនិងអន្តរជាតិ សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការស្រាវជ្រាវនិងអភិវឌ្ឍន៍
- រៀបចំរបាយការណ៍និងលើកអនុសាសន៍ជូន **ក.ជ.វ.ប.ន.** ដើម្បីពិនិត្យនិងតម្រង់ទិសជាដំណោះស្រាយនូវរាល់ការងារប្រឈមផ្សេងៗពាក់ព័ន្ធនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលសម្រេចបាននិងវឌ្ឍនភាពការងារជូន **ក.ជ.វ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន **ក.ជ.វ.ប.ន.**។

**ប្រការ៣ .-**

**គ.ស.អ.** មានសមាសភាពដូចខាងក្រោម៖

- តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រធាន
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១រូប អនុប្រធាន

- តំណាងក្រសួងសុខាភិបាល ១រូប អនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប អនុប្រធាន
- តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប អនុប្រធានអចិន្ត្រៃយ៍
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- តំណាងក្រសួងរ៉ែនិងថាមពល ១រូប សមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
- តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- តំណាងក្រសួងបរិស្ថាន ១រូប សមាជិក
- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប សមាជិក
- តំណាងក្រសួងមហាផ្ទៃ ១រូប សមាជិក
- តំណាងក្រសួងការពារជាតិ ១រូប សមាជិក
- តំណាងក្រសួងផែនការ ១រូប សមាជិក
- តំណាងក្រសួងព័ត៌មាន ១រូប សមាជិក
- តំណាងក្រសួងយុត្តិធម៌ ១រូប សមាជិក
- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- តំណាងក្រសួងទេសចរណ៍ ១រូប សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប សមាជិក
- តំណាងស្ថាប័នសិក្សាស្រាវជ្រាវជាតិពាក់ព័ន្ធនឹងការងារ
  វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មួយចំនួន សមាជិក
- ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងនៃ **គ.ស.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលដោយឡែក។

**គ.ស.អ.** អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិកផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ៤ ._**

**គ.ស.អ.** ត្រូវប្រជុំតាមការចាំបាច់ ។

អនុប្រធាននិងសមាជិក **គ.ស.អ.** ត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានណាម្នាក់តាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីអវត្តមានឬករណីចាំបាច់ ប្រធាន **គ.ស.អ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៥ ._**

**គ.ស.អ.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធនានា និងវិស័យឯកជនចូលរួមពិគ្រោះយោបល់ តាមការចាំបាច់។

**ប្រការ៦ .-**

**គ.ស.អ.** អាចមានក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.វ.ប.ន.**។

**ប្រការ៧ .-**

**គ.ស.អ.** មានលេខាធិការដ្ឋាន **គ.ជ.វ.ប.ន.** ជាសេនាធិការ។

**ប្រការ៨ .-**

**គ.ស.អ.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ **គ.ជ.វ.ប.ន.** សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ